ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍ទ្រាយ

## (២០១៧ - ២០១៩)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ទ្រាយ |
| ភូមិ | ៖ | ទ្រាយ |
| ឃុំ | ៖ | ពោធិ៍ទ្រាយ |
| ស្រុក | ៖ | ពួក |
| ខេត្ត | ៖ | សៀមរាប |

ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍ទ្រាយ
# (២០១៧ - ២០១៩)

សហគមន៍នេសាទ ៖ ទ្រាយ

ភូមិ ៖ ទ្រាយ

ឃុំ ៖ ពោធិ៍ទ្រាយ

ស្រុក ៖ ពួក

ខេត្ត ៖ សៀមរាប

ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៦

# មាតិកា


១.ស្ថានភាពទូទៅ ........ ៤
២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........ ៥
ក.ប្រជាពលរដ្ឋ ........ ៥
ខ. មុខរបរ ........ ៥
៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ........ ៦
ក. ទីតាំង ........ ៦
ខ. ដែននេសាទ ........ ៦
ខ.១.ព្រែក ........ ៦
ខ.២.ត្រពាំង ........ ៧
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៨
ឃ. ធនធានជលផល ........ ៩
១.ប្រភេទត្រី ........ ៩
២.ប្រភេទវារីសត្វ ........ ៩
៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........ ១០
៤.ការធ្វើនេសាទ ........ ១០
ក.អ្នកនេសាទ ........ ១០
ខ.ឧបករណ៍នេសាទ ........ ១១
គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ........ ១២
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២
ក.ទស្សនៈវិស័យ ........ ១២
ខ.គោលបំណង ........ ១២
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១៣
គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ១៤
គ.២. ផែនការកែលម្អដែននេសាទ ........ ១៦
គ.៣. ផែនការរៀបចំកន្លែងអភិរក្ស ........ ១៥
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ១៦
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១៧
គ.៦. ផែនការថវិកាទ្រទ្រង់សម្រាប់ការអភិវឌ្ឍន៍សហគមន៍ ........ ១៨
គ.៧.ផែនការផ្សេងៗ ........ ១៩
គ.៧.១.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១៩
គ.៧.២. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........ ២០
គ.៧.៣. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ........ ២០

គ.៧.៤.ផែនការជួសជុលស្នាក់ការសហគមន៍......................................................................២១
ឃ. យុទ្ធសាស្ត្រ២១
៦.ឧបសម្ពន្ធ
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៧-២០១៩
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៧-២០១៩

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទ្រាយ

## ១- ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយ វិមជ្ឈការ-វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ កន្លងមកភូមិទ្រាយត្រូវបានរៀបចំសហគមន៍នេសាទ ដោយមានការចូលរួមយ៉ាងកុះករពី ប្រជាពលរដ្ឋមូលដ្ឋាន និងបានការគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបជំនាញជលផល និងកិច្ចសហការពីអាជ្ញធរដែនដី ។ ដូចនេះ សហគមន៍នេសាទទ្រាយ ត្រូវបានបង្កើតឡើងដោយមហាសន្និ បាតលើកដំបូងនៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០៥ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៧ ដែលបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដោយបានអនុវត្តចាប់ពីឆ្នាំ ២០០៨ ដល់ ២០១០ ព្រមទាំងត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ខែធ្នូ ឆ្នាំ២០០៨។ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទ្រាយនេះនឹងធ្វើបច្ចុប្បន្នភាព និងរៀបចំលើកទី ២ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៦ ដោយមានចូលរួមពី គណៈកម្មការ និងសមាជិកសហគមន៍នេសាទ ប្រជាពលរដ្ឋ មេភូមិទ្រាយ ក្រុមប្រឹក្សា ជាពិសេសបានការគាំទ្របច្ចេកទេស និងថវិកាពីរដ្ឋបាលជលផលថ្នាក់កណ្តាលនិងសម្របសម្រួលដោយខណ្ឌរដ្ឋបាលជលផលសៀមរាប ។

គណៈកម្មការសហគមន៍នេសាទត្រូវបានបោះឆ្នោតចំនួន ០៣ អណ្តត្តិ រហូតមកដល់ពេលបច្ចុប្បន្ន ព្រមទាំងបានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ ។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទ ត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំ បណ្តាញការងារ ទស្សនកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ ។

ដូច្នេះ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទ្រាយបានធ្វើការកែសម្រួលសកម្មភាព សំខាន់ៗ និងថវិកាដែល គ្រោង ដើម្បីអាចធានាដល់ការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងអភិរក្សសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីធនធានជលផលប្រកបដោយនិរន្តភាព និងសមធម៌។

## ២-អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំពោធិ៍ទ្រាយនេះមានចំនួន ២ ភូមិ ប្រជាពលរដ្ឋសរុបចំនួន ៤២២ គ្រួសារ ហើយមនុស្សសរុបចំនួន ២,១៨៣ នាក់ ក្នុងនោះស្ត្រីចំនួន ១,២២២ នាក់ ដោយឡែកគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ៤៦ គ្រួសារ ។ ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងឃុំពោធិ៍ទ្រាយបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ៤៤ គ្រួសារ និងស្ថានភាពក្រីក្រ ២ មានចំនួន ៣៣ គ្រួសារ ដែលសរុបចំនួន ៧៧ គ្រួសារ ។ ដោយឡែកសហគមន៍នេសាទទ្រាយគ្របដណ្តប់តែមួយភូមិដែលហៅថា ភូមិទ្រាយ ដោយមានប្រជាពលរដ្ឋសរុបចំនួន ៣១០ គ្រួសារ ដែលមានមនុស្សសរុបចំនួន ១,៦១៦ នាក់ ក្នុងនោះស្ត្រីចំនួន ៩១៧

នាក់ និងគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន ៣២គ្រួសារ ។ ចំនួនគ្រួសារដែលចូលជាសមាជិកសហគមន៍នេសាទមានតែចំនួន ២៩៥ គ្រួសារ ។

សហគមន៍នេសាទទ្រាយមានប្រជាពលរដ្ឋជាជនជាតិខ្មែរហើយគោរពព្រះពុទ្ធសាសនាដែលមានស្ថានភាពដូចជាៈ

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងសហគមន៍ទ្រាយបានបង្ហាញថា គ្រួសារ ដែលស្ថិតក្នុងស្ថានភាពក្រីក្រ ១ មានចំនួន ៣៧ គ្រួសារ និងស្ថានភាពក្រីក្រ២មានចំនួន០៧ គ្រួសារ ដែលសរុបចំនួន ៤៤ គ្រួសារ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៣ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន ០៣ នាក់ ក្នុងនោះស្ត្រីមានចំនួន ០១នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ០៣ នាក់ ក្នុងនោះកុមារីមានចំនួន ០២ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១១ នាក់ក្នុងនោះស្ត្រីមានចំនួន ០៨ នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ១០ នាក់ ក្នុងនោះស្ត្រីមានចំនួន ៦ នាក់
- សាលារៀនបឋមសិក្សាសុខាល័យមានចំនួន ០២ ខ្នង ដែលមាន ០៦ បន្ទប់ មានសិស្សសរុបចំនួន ២៧៤ នាក់ ក្នុងនោះកុមារីមានចំនួន ១៧២ នាក់។

### ខ.សេដ្ឋកិច្ចសង្គម

តាមរបាយការណ៍ និងឯកសារព័ត៌មានឃុំឆ្នាំ ២០១៦ បានបញ្ជាក់ថា នៅក្នុងសហគមន៍ទ្រាយ មានប្រជាពលរដ្ឋសរុបចំនួន ៣១០ គ្រួសារ ដែលពឹងផ្អែកលើការនេសាទ និងការចិញ្ចឹមត្រី ក្រៅពីនេះ រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជា កែច្នៃផលត្រី ផ្តល់ចំណីត្រី និងលក់ដូរ ជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទទ្រាយ ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមានៈ

#### ខ.១.អ្នកដែលមានមុខរបរនេសាទ និងធ្វើអាជីវកម្មផ្សេងៗដូចជាៈ

- ជាអ្នកនេសាទ អ្នកចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងដាំបន្លែមានចំនួន ១០៧ គ្រួសារ
- ប្រមូលទិញ លក់ផលត្រី និងនេសាទមានចំនួន ៣ គ្រួសារ
- ជាអ្នកចិញ្ចឹមត្រីរស់ ចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងនេសាទចំនួន ១៤៥ គ្រួសារ
- ជាអ្នកចិញ្ចឹមត្រីអណ្តែង ចិញ្ចឹមសត្វលក្ខណៈគ្រួសារ និងនេសាទចំនួន ២៥ គ្រួសារ
- អ្នកកែច្នៃផលត្រី និងនេសាទដូចជាៈ ធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន ៧ គ្រួសារ
- រត់ទូកដរ និងនេសាទមានចំនួន ០២ គ្រួសារ

- គ្រូបង្រៀន និងនេសាទ ០៣ គ្រួសារ

**ខ.២.អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ**

- អ្នកលក់ដូរ ៦ គ្រួសារ
- ជាងធ្វើមាស៊ីនកាណូត ០២ គ្រួសារ

## ៣- កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក.ទីតាំង

សហគមន៍នេសាទទ្រាយមានទីតាំងស្ថិតក្នុងភូមិទ្រាយ ដែលជាដែននេសាទសាធារណៈរបស់រដ្ឋដែលជាដែននេសាបទឹកសាបក្នុងខេត្តសៀមរាប ។ កន្លែងនេសាទសហគមន៍នេះមានទំហំ ១១៩៧ ហិកតា ហើយមានកន្លែងអភិរក្សពូជត្រីសំខាន់ៗចំនួន ២ កន្លែង ។ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។ ដូចនេះ សហគមន៍នេសាទទ្រាយមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹងមុខប៉ែន
- ខាងត្បូងទល់នឹងឃុំកោះជីវាំង និងស្ទឹងសង្កែ
- ខាងកើតទល់នឹងសហគមន៍នេសាទល្វា
- ខាងលិចទល់នឹងសហគមន៍ភូមិ និងស្ទឹងសង្កែ។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទទ្រាយ មានវិសាលភាពនៅក្នុងទន្លេបឹងទន្លេសាបដែលគ្រប់ ដណ្តប់លើកន្លែងនេសាទបឹងទន្លេសាប កន្លែងអភិរក្សពូជត្រី ព្រែក ត្រពាំង និងអន្លង់សំខាន់ៗ មួយចំនួនដូចជា៖

**ខ.១ ព្រែក**

| ល.រ | ឈ្មោះព្រែក | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ព្រែកទ្រាយ | ៣,៥ | ខែ ១២ - ខែ ០៤ |
| ២ | ព្រែកល្មៀង | ២,០១ | ខែ ១២ - ខែ ០៤ |
| សរុប | | ៥,៥ | |

**ខ.២.បឹង**

| ល.រ | ឈ្មោះបឹង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | បឹងកំពីងពួយ | ១,៥១ | ខែ ០១ - ខែ ០៣ |
| ២ | បឹងអូរក្របីដេក | ១,៨២ | ខែ ០១ - ខែ ១២ |
| ៣ | បឹងច្រាំងចោត | ២,៧៤ | ខែ ០១ - ខែ ១២ |
| ៤ | បឹងគ្រាវ | ០,២៨ | ខែ ០១ - ខែ ០៥ |
| | សរុប | ៦,៣៥ | |

ខ.៣.ត្រពាំង

| ល.រ | ឈ្មោះត្រពាំង | ទំហំជា ហត | រដូវនេសាទ |
|---|---|---|---|
| ១ | ត្រពាំងប្រលាន | ១,៦ | ខែ ០១ - ខែ ០៣ |
| ២ | ត្រពាំងជេម្ពាយ | ០,៩៥ | ខែ ០១ - ខែ ០៣ |
| ៣ | ត្រពាំងប្រូបាយ | ០,៨៥ | ខែ ០១ - ខែ ០៣ |
| ៤ | ត្រពាំងថ្មតូច | ១,៥៥ | ខែ ០១ - ខែ ០៣ |
| ៥ | ត្រពាំងថ្មធំ | ២,០៥ | ខែ ០១ - ខែ ០៣ |
| ៦ | ត្រពាំងទទឹងថ្ងៃ | ០,២២ | ខែ ០១ - ខែ ០៣ |
| ៧ | ត្រពាំងកេ | ០,២៦ | ខែ ០១ - ខែ ០៣ |
| ៨ | ត្រពាំងជេងគ្រួស | ០,២៨ | ខែ ០១ - ខែ ០៣ |
| ៩ | ត្រពាំងសណ្តាន់ | ០,៣៤ | ខែ ០១ - ខែ ០៣ |
| ១០ | ត្រពាំងរនាល | ០,១៥ | ខែ ០១ - ខែ ០៣ |
| ១១ | ត្រពាំងកន្សែងភ្លោះ | ០,៤០ | ខែ ០១ - ខែ ០៣ |
| ១២ | ត្រពាំងបែកថ្លាង | ១,៦៥ | ខែ ០១ - ខែ ០៣ |
| ១៣ | ត្រពាំងរហាលទៀង | ០,៥១ | ខែ ០១ - ខែ ០៣ |
| ១៤ | ត្រពាំងរហាលទ្រាយ | ០,៤៣ | ខែ ០១ - ខែ ០៣ |
| ១៥ | ត្រពាំងផ្ទោល | ០,៧៤ | ខែ ០១ - ខែ ០៣ |
| ១៦ | ត្រពាំងស្បូវ | ០,៥១ | ខែ ០១ - ខែ ០៣ |
| | សរុប | ១២,៧៣ | |

កន្លែងនេសាទសហគមន៍ទ្រាយបានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅ និងការធ្វើអាជីវកម្មនេសាទនៅក្នុងសហគមន៍ ក៏ដូចអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេស កន្លែងនេសាទសហគមន៍មានអំណោយផលល្អដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិ ជាពិសេសជាចំណី និងជម្រកពងកូនរបស់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ។ ម្យ៉ាងទៀត កន្លែងនេសាទសហគមន៍ទ្រាយជាក់ស្តែងបានភ្ជាប់ជាមួយបឹង ព្រែក អូរ និងត្រពាំងដែលទទួលរបបទឹកពីបឹងទនេសាប ហើយបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់កសិកម្ម។

ដែននេសាទសំខាន់ៗនៅក្នុងសហគមន៍ទ្រាយមានព្រែកចំនួន ០២ ព្រែក ដែលមានទំហំប្រមាណ ៥,៥ ហិកតា បឹងចំនួន ០៤ បឹង ដែលមានទំហំប្រមាណ ៦,៣៥ ហិកតា និងត្រពាំងមានចំនួន ១៧ ត្រពាំង ដែលមានទំហំប្រមាណ ១២,៧៣ ហិកតា ។ ដោយឡែក កន្លែងនេសាទសហគមន៍ទ្រាយមានដូចជា៖ ព្រៃលិចទឹកមានទំហំប្រហែល ៦៩០ ហិកតា តំបន់វាលស្មៅ និងកន្លែងនេសាទមានទំហំប្រហែល ៤៧៧,៩២ ហិកតា ផ្សេងៗដែលមិនបង្ហាញលំអិតក្នុងចំនុច ខ.១ ខ.២ និងខ.៣ និងកន្លែង អភិរក្សចំនួន ០២ កន្លែងដែលមានទំហំ ៤,៥ ហត ។ ដូច្នេះ កន្លែងនេសាទសហគមន៍ទ្រាយមានទំហំសរុប ១,១៩៧ ហិកតា ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទទ្រាយបានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែងគឺ ប្រាំងស្បូវដែលមានទំហំប្រហែល ២ ហិចតា និងត្រពាំងវៀនមានទំហំប្រហែល ២,៥ ហិចតា ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ។ ដូចនេះផងដែរ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍នេសាទ កន្លែងអភិរក្សត្រីមេពូជទាំងនេះមានដូចខាងក្រោម៖

| ល.រ | ឈ្មោះអន្លង់ | ទំហំជា ហត | ការអភិរក្ស |
|---|---|---|---|
| ១ | ប្រាំងស្បូវ | ២ | កន្លែងអភិរក្សត្រីមេពូជ |
| ២ | ត្រពាំងវៀន | ២,៥ | កន្លែងអភិរក្សត្រីមេពូជ |
| | សរុបទំហំគិតជាហិចតា | ៤,៥ | |

**ឃ.ធនធានជលផល**

**១.ប្រភេទត្រី៖**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ ។ តាមការបង្ហាញពីសហគមន៍ទ្រាយបានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលបានថយចុះ ជាពិសេសក្នុងឆ្នាំ ២០១៥ ដោយសារមានការប្រែប្រួលអាកាសធាតុដែលធ្វើឲ្យបឹង និងព្រៃរីងរាក់ ហើយធ្វើឲ្យប្រភេទត្រីមេពូជត្រូវបាននេសាទយកស្ទើរតែទាំងអស់។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍ ធនធានជលផលក្នុងសហគមន៍នេសាទទ្រាយមានដូចជា៖

**ឃ.១.ប្រភេទត្រី:**

ក្នុងសហគមន៍នេសាទមាត់ខ្លាមានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្តាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីឆ្អែក ត្រីគ្រំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ធប់ ត្រីប្រម៉ា ត្រីក្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្នឹង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្ពោក ត្រីកញ្ចុះភ្លោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំផ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្កៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្អម ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីឆ្អែក ត្រីលិញ ។ល។

**ឃ.២.ប្រភេទវារីសត្វ:**

ក្នុងសហគមន៍នេសាទទ្រាយ មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់កង្កែប ហ៊ឹង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ គេ សត្វស្វាក្រុះ សំពោច ។ល។

**ឃ.៣.ប្រភេទបក្សី:**

ក្នុងសហគមន៍នេសាទទ្រាយមានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវឹក សត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាប សត្វត្រយង សត្វនាលខ្យង សត្វក្រដក់ សត្វក្រសា សត្វកំពឹងដូង។ល។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ក្នុងសហគមន៍នេសាទ មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើមតាអួរ ដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្មាចទឹក ដើមកណ្តាប់ចង្កេះ ដើមរំដេញ ដើមបន្ទាស្អិត ដើមច្រកែង ។ល។

**៤.ការធ្វើនេសាទ៖**

នេសាទជាមុខរបរចាំបាច់សម្រាប់ការចិញ្ចឹមជីវិតរបស់សហគន៍នេសាទទ្រាយ និងផលិតផលត្រីត្រូវបានធ្វើអាជីវកម្មក្នុងតំបន់ផ្ទាល់ដើម្បីរកចំណូល ហើយនាំបានចេញមកទីក្រុងក្នុងប្រទេស ព្រមទាំងបានធ្វើពាណិជ្ជកម្មក្រៅប្រទេសទៀតផង។ ពេលបច្ចុប្បន្ន ប្រជាពលរដ្ឋទាំងអស់ក្នុង សហគមន៍នេះបានផ្តោតលើកានេសាទ ដោយបានប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារក្នុងការទាញយកផលនេសាទ ប៉ុន្តែការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ ជាពិសេសផែនការគ្រប់គ្រងរបស់សហគមន៍ដែលបានរៀបចំសម្រាប់ឆ្នាំ ២០០៨ដល់ឆ្នាំ ២០១០។ ទោះបីជានៅមានជនល្មើសខ្លះបានប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅលើកន្លែងនេសាទសហគមន៍ទ្រាយ ជាពិសេស នៅក្នុងកំឡុងឆ្នាំ ២០១៥ ដែលមានបញ្ហាគ្រោះរាំងស្ងួតបានធ្វើឱ្យបឹង ព្រែក និងត្រពាំងបារីងរាក់ ហើយប្រភេទត្រីមេពូជបាននេសាទដោយជនល្មើស ។

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍នេសាទទ្រាយបានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍ទ្រាយ មានដូចខាងក្រោម៖

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២៩៥ គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍ទ្រាយមានចំនួន ២០គ្រួសារ
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍ទ្រាយមានប្រហែល ១៥០ គ្រួសារ ក្នុង១ឆ្នាំ ។

**៤.ខ.ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទ ប្រជាជននៅក្នុងសហគមន៍នេសាទទ្រាយ និងអ្នកខាងក្រៅតែងតែធ្វើនេសាទដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារដូចជា៖ លប មង សន្ទូច លបព្រៀង ឡើ លាន់ និងផុច។ល។ ដូចនេះ សមាជិក និងគណៈកម្មការសហគមន៍នេសាទទ្រាយបានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេស សមាជិក និងគណៈកម្មការសហគមន៍នេសាទនេះ ទាមទារសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយច្រើនដងដល់ប្រជាពលរដ្ឋក្នុសហគមន៍ និងអ្នកនេសាទខាងក្រៅ លើប្រភេទឧបករណ៍នេសាទដែលហាមឃាត់ដូចជា៖ ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង ។ល។

ឧបករណ៍នេសាទ និងទូកការល្បាតរបស់សមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់ក្នុងសហគមន៍ទ្រាយដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងព្រុយុង | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ខែ ០១ ដល់ ខែ ១២ |
| ២ | សន្ទូចបបក់ | ផ្លែ | ១ ផ្លែ | ខែ ០១ ដល់ ខែ ០១ |

| | | | | |
|---|---|---|---|---|
| ៣ | សន្ទូចរនង | ផ្លែ | ៥០០ | ខែ ០៨ ដល់ ខែ ១២ |
| ៤ | លបព្រៀង | លប | ៣០ | ខែ ១០ ដល់ ខែ ១២ |
| ៥ | ដាក់ឡើ | ឡើ | ១០០ | ខែ ១១ ដល់ ខែ ០៣ |
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ខែ ១១ ដល់ ខែ ០៣ |
| ៧ | ជុច | ជុច | ១០០ | ខែ ០៣ ដល់ ខែ ០៦ |
| ៨ | សំណាញ់ | សំណាញ់ | ១ វង់ | ខែ ០១ ដល់ ខែ ០៤ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន Hynota | ១៩៥ | ៥០០ | ៦ ដល់ ១៨ |
| កាណូតពីរម៉ាស៊ីន Cava | ៨ | ៦០០ | ១៦០ |
| ទូកអុំ ឬទូកចែវ | ២០ | ១០០ | |

**ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ**

| ប្រភេទឧបករណ៍ | ឯកតា | ទំហំ/ប្រវែង | រដូវនេសាទ |
|---|---|---|---|
| មងព្រាយុង | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ខែ ០១ ដល់ ខែ ១២ |
| សន្ទូចបបក់ | ផ្លែ | ១ ផ្លែ | ខែ ០១ ដល់ ខែ ០១ |
| លបព្រៀង | លប | ៣០ លប | ខែ ១០ ដល់ ខែ ១២ |
| ដាក់លាន់ | លាន់ | ២០ លាន់ | ខែ ១១ ដល់ ខែ ០៣ |
| ជុច | ជុច | ១០០ ជុច | ខែ ០៣ ដល់ ខែ ០៦ |

នៅរដូវប្រាំង ជាញឹកញាប់អ្នកខាងក្រៅ ធ្វើដំណើរមកការនេសាទដែននេសាទសហគមន៍នេសាទទ្រាយ ដោយមធ្យោបាយផ្សេងៗ ដែលចង្អុលបង្ហាញក្នុងតារាងខាងក្រោម៖

| មធ្យោបាយធ្វើដំណើរ | ចំនួន(គ្រឿង) | ចំណុះ(គក) | ផ្សេងៗ |
|---|---|---|---|
| គោយន្ត | ៦០ | ១០០០ | |
| រទេះ | ៣០ | ៥០០ | |
| ម៉ូតូ | ៦០ | ១០០ | |

ចំណែកនៅរដូវវស្សា អ្នកខាងក្រៅធ្វើដំណើរមកការនេសាទដែននេសាទសហគមន៍នេសាទទ្រាយ ដោយមធ្យោបាយផ្សេងៗ ដែលចង្អុលបង្ហាញក្នុងតារាងខាងក្រោម៖

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន Hynota | ២ | ៥០០ | ៦ ដល់ ១៨ |
| ទូកអុំ ឬទូកចែវ | ២០ | ១០០ | |

### គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យម |
|---|---|

| | ប្រចាំគ្រួសារ(គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៣,៥០០ | ៥,៥០០ | ៩,០០០ |
| ក្តាម ខ្យង ខ្ចៅ និងលៀស | ២៥០ | ៣៥០ | ៦០០ |
| អន្ទង់ | ៣៥០ | ៤៥០ | ៨០០ |
| សរុប | ៤,១០០ | ៦,៣០០ | ១០,៤០០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទទ្រាយមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងនិរន្តរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកជំនើង ព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

#### គោលបំណង

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ ,រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និង រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងព្រយុង | ម៉ែត្រ | ៤៥ម x១,៥ម x០,០៣៥ម | ពីខែ ០២ ដល់ ខែ ០៤ |
| ២ | សន្ទូចបបក់ | ផ្លែ | ១ ផ្លែ | ខែ ០១ ដល់ ខែ ០១ |
| ៣ | សន្ទូចរនង | ផ្លែ | ៥០០ | ខែ ០៨ ដល់ ខែ ១២ |
| ៤ | លបព្រៀង | លប | ៣០ | ខែ ១១ ដល់ ខែ ១២ |
| ៥ | ដាក់ឡើ | ឡើ | ១០០ | ខែ ១០ ដល់ ខែ ០២ |

| | | | | |
|---|---|---|---|---|
| ៦ | ដាក់លាន់ | លាន់ | ៦៥ | ខែ ០៨ ដល់ ខែ ១២ |
| ៧ | ផុច | ផុច | ១០០ | ខែ ០១ ដល់ ខែ ០១ |
| ៨ | សំណាញ់ | សំណាញ់ | ១ វង់ | ខែ ០១ ដល់ ខែ ០៤ |

| ល.រ | ឈ្មោះ/ទីតាំង កន្លែង នេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | |
|---|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង/ គ្រួសារ | ចំនួន គ្រួសារ |
| ១ | ព្រែកទ្រាយ | ខែ០៨-ខែ០២ | សន្ទូចរនង មង សន្ទូច បបក់ឡើ លាន់ លប | ៥០០ផ្លែ១ផ្លែ១០០ឡើ/ ៦៥លាន់/៣០លប | ១៥០ |
| ២ | ព្រែកល្បៀង | ខែ០៨-ខែ០២ | សន្ទូចរនង មង សន្ទូច បបក់ឡើ លាន់ លប | ៥០០ផ្លែ១០០ឡើ/ ៦៥លាន់/៣០លប | ៩០ |
| ៣ | បឹងកំពឹងពួយ | ខែ០៨-ខែ០២ | សន្ទូចរនង មងព្រយុង លាន់ លប | ៥០០ផ្លែ៤៥ម១០០ ឡើ/៦៥លាន់/៣០លប | ៣០ |
| ៤ | បឹងអូរក្របីដេក | ខែ០៨-ខែ០២ | សន្ទូចរនង សន្ទូចបបក់ ឡើ លាន់ លប | ៥០០ផ្លែ១ផ្លែ១០០ ឡើ/៦៥លាន់/៣០លប | ២០ |
| ៥ | បឹងប្រាំងចោត | ខែ០៨-ខែ០២ | សន្ទូចរនង មងព្រយុង លាន់ លប | ៥០០ផ្លែ៤៥ម១០០ ឡើ/៦៥លាន់/៣០លប | ១៥ |
| ៦ | បឹងត្រាវ | ខែ០៨-ខែ០២ | សន្ទូចរនងមងព្រយុង សន្ទូចបបក់ឡើលាន់ លប | ៥០០ផ្លែ៤៥ម១ផ្លែ ១០០ឡើ/៦៥លាន់/៣០លប | ១៥ |
| ៧ | ត្រពាំងប្រលាន | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ៨ | ត្រពាំងដេម្លាយ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៧ |
| ៩ | ត្រពាំងប្រូបាយ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ១០ | ត្រពាំងថ្មតូច | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ១១ | ត្រពាំងថ្មធំ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ១២ | ត្រពាំងទទឹងថ្ងៃ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ១៣ | ត្រពាំងភេ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ១៤ | ត្រពាំងជេងគ្រួស | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៧ |
| ១៥ | ត្រពាំងសណ្តាន់ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៦ |
| ១៦ | ត្រពាំងរនាល | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ១៧ | ត្រពាំងកន្សែងភ្លោះ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ១៨ | ត្រពាំងបែកថ្លាង | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ១៩ | ត្រពាំង | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ២០ | ត្រពាំងរហាលទៀង | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |

| | | | | | |
|---|---|---|---|---|---|
| ២១ | ត្រពាំងរហាលទ្រាយ | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៨ |
| ២២ | ត្រពាំងផ្តោល | ខែ០១-ខែ០៤ | មងព្រយុង សំណាញ់ | ៤៥ម១ វង់ | ៩ |
| ២៣ | ដែននេសាទផ្សេងៗ ដែលមិនបារៀបរាប់ខាងលើ សម្រាប់សហគមន៍នេះ | ខែ០៨-ខែ០២ | សន្ទូចរនង មងព្រយុង សន្ទូចបបក់ឡើ លាន់ លប | ៥០០ផ្លៃ៤៥ម ១ផ្លៃ ១០០ឡើ/៦៥លាន់/៣០លប | ៧០ |

**គ.២.ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថា ការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះៗ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទទ្រាយមានសភាពប្រែប្រួលខ្លះ ដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ ដូចជាព្រែកដែលធ្វើចរាចរទទួលនូវការរីងរាក់ដែលបណ្តាលមកពីការដាក់ក្នុងព្រែក និងការហូរច្រោះដោយសារការកាប់ទន្រ្ទាញព្រៃលិចទឹកនៅតាមមាត់ព្រែក ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទ នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ស្តារប្រឡាយខ្មោច | ៦,៥ គម | ៣០០ ម | ធ្វើការសិក្សា | ខែតុលា ២០១៨ | ខែធ្នូ២០១៨ |
| | | | ស្តារប្រឡាយខ្មោច | ខែមករា ២០១៩ | ខែធ្នូ ២០១៩ |

**គ.៣ ផែនការរៀបចំកន្លែងអភិរក្ស**

សហគមន៍នេសាទទ្រាយបានសម្រេច ក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០២ កន្លែង គឺ ប្រាំងស្បូវ និងត្រពាំងវៀន ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទទ្រាយ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត និងពិនិត្យរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិសហគមន៍នសាទនេះ បានបញ្ជាក់ថា៖ បឹងប្រាំងស្បូវ និងត្រពាំងវៀន គឺជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការ

អភិរក្សដែលសមាជិកសហគមន៍នេសាទទ្រាយ មានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តារខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិចតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បឹងប្រាំងស្បូវ | ២ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • បោះបង្គោលស៊ីម៉ង់បន្ថែមចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ចុះល្បាតជាប្រចាំ | ២០១៧ | ២០១៨ |
| គ្រពាំងវៀន | ២,៥ | • ប្រភេទត្រីសំខាន់<br>• ប្រភេទសត្វស្លាប<br>• ប្រភេទពពួកល្មូន<br>• ព្រៃលិចទឹក | • សិក្សាពីកន្លែងអភិរក្ស<br>• បោះបង្គោលចំនួន ៧ ដើម<br>• ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០១៨ | ២០១៩ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹកបានគ្របដណ្តប់លើដែននេសាទសហគមន៍ទ្រាយ ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូន និងជាចំណីផងដែរ។ដូចនេះផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង៖

- ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នសាទបានកំណត់ និងបែងចែកនាទីព្រៃលិចទឹកមាន កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់រំលោះដោយផ្អែកតាមដែនទីសហគមន៍នេសាទ។កន្លែងប្រើប្រាស់ព្រៃលិចទឹក ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឲ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។ ការកាប់រំលោះនេះ ធ្វើជាលក្ខណវិលជុំជារៀងរាល់បីឆ្នាំម្តង ដើម្បីទុកឱ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយសារការយល់ដឹងពីសារៈសំខាន់នៃនាទីព្រៃលិចទឹក ប្រជាពលរដ្ឋមានការចូលរួមចំណែកយ៉ាងសកម្ម ក្នុងការគ្រប់គ្រងធនធានជលផលឱ្យប្រសើរឡើង ។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍ទ្រាយមានដូចជា៖

| ឈ្មោះ /ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ដាំព្រៃលិចទឹកនៅបឹងប្រាំងស្បូវ | ០,៥ ហិកតា | រាំង ផ្ទោល ក្តួរ និងច្រកែង ។ល។ | • ផ្សព្វផ្សាយពីផលប្រយោជន៍នៃការគ្រប់គ្រងព្រៃលិចទឹក | ១៨/១/១៧ | ២២/១/១៨ |
| | | | • រៀបចំកូនឈើ | ២៧/៥/១៧ | ០៥/៦/១៨ |
| | | | • ដាំកូនឈើ និងដាក់ស្លាកសញ្ញា | ១០/៦/១៧ | ១៣/៦/១៨ |
| | | | • ថែរក្សា និងការពារ | ១៣/៦/១៧ | ៣០/៩/១៨ |
| ថែរក្សនិងការពារព្រៃលិចទឹក | ៦៨៥,៥ ហត | ព្រៃលិចទឹកគ្រប់ប្រភេទ | • ផ្សព្វផ្សាយផែនការ គ្រប់គ្រងព្រៃលិចទឹក | ៣/១/១៩ | ៥/១/១៩ |
| | | | • ដាក់ស្លាកសញ្ញាការពារ | ៥/៣/១៩ | ១០/៣/១៩ |
| | | | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

**គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគន៍ទ្រាយនេះ ។ ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីនៅតាមស៊ង និងបែរដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ ត្រីប្រា និងត្រីអណ្តែង។ល ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឲ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៣២៥ ប្រក កសកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទទ្រាយបានផ្តោតសំខាន់លើការចិញ្ចឹមត្រីតាមបែរដែលការចិញ្ចឹមត្រីមានដូចជា៖ ត្រីរ៉ស់ និងត្រីអណ្តែង ពីព្រោះសហគមន៍នេះស្ថិតក្បែរបឹងទន្លេសាបដោយមានព្រែកតភ្ជាប់ជាមួយបឹងទន្លេសាប។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទទ្រាយក្នុងគោលបំណង ៖

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ

• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទទ្រាយ បានរៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ ចាប់ផ្តើម | ខែ/ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីរ៉ស់តាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែបឬស្សីចំនួន ២៥គ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>• ធ្វើបែបឬស្សីចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ២៥ បែ ទំហំ ៥ម X ៣ ម ត្រីរ៉ស | ត្រីរ៉ស់ | ៣,៥០០ /គ្រួសារ | ១០/៩/១៧ | ៣០/៩/១៧ |
| ចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែបឬស្សី ចំនួន ១៥ គ្រួសារ | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>• ធ្វើបែបចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ១៥ បែ ទំហំ ៥ម X ២,៥ ម ត្រីអណ្តែង | | ៤,០០០/ គ្រួសារ | ១២/៧/១៩ | ២៥/៧/១៩ |

**គ.៦.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សម្បុរសជនក្រុមប្រឹក្សាឃុំ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ ។

ដូចនេះ ផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍នេះ មានក្នុងតារាងខាងក្រោះ៖

| ប្រភេទចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូល(រៀល) |
|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយ និងបណ្ណភាគទាន | ២០១៧ | ២០១៩ | ១៥៥.០០០ |
| ភាគទានពីអ្នកនេសាទខាងក្រៅ | ចេញបណ្ណភាគទាន | ២០១៧ | ២០១៩ | ៤៥០.០០០ |
| សម្បុរសជន អង្គការដៃគូ | ការពារធនធានធម្មជាតិ | ២០១៧ | ២០១៩ | ៧.០០០.០០០ |

| និងក្រុមប្រឹក្សាឃុំ | | | | |
|---|---|---|---|---|

### គ.៧ ផែនការផ្សេងៗទៀត

### គ.៧.១. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

